ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៤ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៤នេះ ស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៤ ត្រូវបានបញ្ចប់ជាស្ថាពរហើយ បើប្រៀបធៀបរយៈពេលដូចគ្នាគឺលើសឆ្នាំមុន១.៦៦៤ហិកតា។ ទន្ទឹមនឹងនោះ នៅតាមបណ្តាខេត្តមួយចំនួនដែលទទួលរងនូវផលប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិនោះ ប្រជាកសិករកំពុងជំរុញការងារប្រមូលផលដំណាំផ្សេងៗ និងស្តារផ្ទៃដីខូចខាត ហើយបាននឹងកំពុងជំរុញការដាំដុះដំណាំស្រូវរដូវប្រាំងយ៉ាងមមាញឹក។ ជាមួយនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការខិតខំថែទាំដំណាំស្រូវ យកចិត្តទុកដាក់លើការគ្រប់គ្រង និងការប្រើប្រាស់ទឹកឲ្យមានប្រសិទ្ធភាព ក៏ដូចជាការថែទាំដំណាំផ្សេងៗ និងរក្សាទឹកទុកឲ្យបានគត់មត់នៅចុងរដូវវស្សា ព្រមទាំងជំរុញការធ្វើកសិកម្មចម្រុះឲ្យអស់ពីលទ្ធភាពដែលមានប្រភពទឹកនៅជិត។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ នេះមានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ រដូវវស្សាឆ្នាំ២០១៤

ជារួមផ្ទៃដីអនុវត្តសរុបចំនួន២.៥៦៤.៤២៨ហិកតា ស្មើនឹង១០៦,៣៥ភាគរយ នៃផែនការ២.៤១១.២០៧ហិកតា លើសឆ្នាំមុនចំនួន១.៦៦៤ហិកតា ក្នុងនោះ ការងារប្រមូលផលស្រូវស្រាលសម្រេចបានលើផ្ទៃដីសរុបចំនួន៩៩៥.៦៣៣ ហិកតា លើសឆ្នាំមុន១៣៤.៣៨៥ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន២.៧៤០.០៧០តោន លើសឆ្នាំមុន ២៥៥.៤៨៧តោន និងទិន្នផលជាមធ្យមចំនួន២,៧៥២តោនក្នុងមួយហិកតា(ឆ្នាំមុនទិន្នផលមធ្យម២,៨៨៥តោនក្នុងមួយហិកតា)។

#### ១.២ រដូវប្រាំងឆ្នាំ២០១៤

##### ១.២.១ ដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៤

- ផ្ទៃដីភ្ជួររាស់សរុបចំនួន២២២.១០៩ហិកតា លើសឆ្នាំមុនចំនួន២២.៨០៦ហិកតា
- ផ្ទៃដីសាបសរុបចំនួន២.៥៧០ហិកតា លើសឆ្នាំមុនចំនួន១៨៧ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន១៨១.១៥៣ហិកតា ស្មើនឹង៤៤,១៧ភាគរយនៃផែនការ៤១០.១៣០ ហិកតា លើសឆ្នាំមុនចំនួន៧៧.៨៦២ហិកតា។

##### ១.២.២ ដំណាំរួមផ្សំ

ផ្ទៃដីសម្រេចបានចំនួន១៦.៤៤៦ហិកតា ស្មើនឹង៣៨,៩៣% នៃផែនការចំនួន៤២.២៤៤ហិកតា លើសឆ្នាំមុនចំនួន៧.៩៥៩ហិកតា។



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

### ១.២.៣ ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន២.១៧៦ហិកតា ស្មើនឹង១០,៧៥% នៃផែនការ២០.២៥១ហិកតា លើសឆ្នាំមុនចំនួន៥១០ហិកតា។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៤៤,៣១ | ៥៣២,៦៣ | ៤៧៥,00 |
| សរុប I | | ៤០៦,៦០ | ៣៤៤,៣១ | ៥៣២,៦៣ | ៤៧៥,00 |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១០.៧១៩,២៧ | ៥.៣២៧,០៥ | ១២.៩៩៨,៦៦ | ៨.៩៣៤,៨៨ |
| ២ | ក្រុមហ៊ុន ស៊ីហ្សាំប់ប៊ើលីមីធីត (រតនគីរី) | ៧៨,៥៣ | ២.០៦៤,៣០ | ៥៤២,១៨ | ១00.00 |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៥១,៨០ | ១.០៨២,១២ | ៩២១,២០ | ៨២៦,00 |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.៥៧១,៥២ | ៣.០៥៨,២៧ | ៤.៤១៥,៧៣ | ៣.៧៧៤,៨0 |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.៣៤៦,៦៩ | ៣.០៩០,១៩ | ២.៣៦២,៥៦ |
| ៦ | ក្រុមហ៊ុន ស៊ីហ្សវីសសស់ (ស្នួល) | ១.៦២៣,២០ | ២.៧៦៣,០១ | ១.៧៨៨,០៣ | ១.៤៨៦,៨0 |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.០២៩,៧០ | ១.២៣៧,៥៩ | ១.៣៥៣,៩៣ | ១.០៣១,២០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ២.០៣៨,00 | ៣.៤៦៩,៧៩ | ១.៤៦៤,៥៧ | ១.១៩៨,៨0 |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ៨៧៥,៦៦ | - | - |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.៣៩៣,៥៥ | ២.៣៤៧,៩២ | ៤.២០៣,៤២ | ៣.៣១៣,៤0 |
| សរុប II | | ២៦.៩៦៤,៣១ | ២៧.៥៧២,៤0 | ៣០.៧៧៧,៩១ | ២៣.០៦៨,៤៤ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៧០៨.00 | ១៩១.២០៤,00 | - | - |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៦១.២៧១,00 | ៧៦.១៤៧,00 | ៤៧.៩១១,00 | ៤៧.៩១១,00 |
| សរុប III | | ៦១.៩៧៩,00 | ២១៧.៣៥១,00 | ៤៧.៩១១,00 | ៤៧.៩១១,00 |
| សរុប I+II+III | | ៨៩.៣៤៩,៩១ | ២៤៥.២៦៧,៧១ | ៧៩.២២១,៥៤ | ៧១.៤៥៤,៤៤ |

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បើកវគ្គបណ្តុះបណ្តាលស្តីពី"អត្តសញ្ញាណកម្មក្លូនកៅស៊ូ" នៅស្ថានីយអនុវត្ត ដែលមានអ្នកចូលរួមចំនួន៣២នាក់ មកពីបណ្តាខេត្តនិងក្រុមហ៊ុន
- ធ្វើតេស្តសំណាកយថាប្រភេទចំនួន៣៦សំណាក ដើម្បីបញ្ជាក់គុណភាពកៅស៊ូរបស់រោងចក្រក្រុមហ៊ុន Mekong Green Farm និងការធ្វើតេស្តវិភាគលទ្ធផលលើកៅស៊ូប្រភេទ CV60 ក្រុមហ៊ុនចម្ការកៅស៊ូជុប
- បាញ់ថ្នាំការពារជំងឺកូនកៅស៊ូបានចំនួន៣ដង និងព្យាបាលជំងឺផ្កាកូលាបលើកទី៤
- វាស់ទំហំដើមកៅស៊ូនិងតាមដានទិន្នផលជ័រលើចម្ការពិសោធន៍ដីលើក្លូន PB260, PB217 និងវិភាគសរីរទឹកជ័រ តាមចម្ការពិសោធន៍នីមួយៗ
- ដឹកនាំនិស្សិតសរសេរសារណាបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យស្វាយរៀង និងសាលាជាតិកសិកម្មកំពង់ចាម
- កាប់ព្រៃតាមចន្លោះរងក្នុងឡូត៍នីមួយៗ លាបថ្នាំរំញោចនិងលាបខ្លាញ់គោ ព្រមទាំងបាញ់ថ្នាំការពារជំងឺកូនកៅស៊ូ ដាក់ជីលើកូនកៅស៊ូតាមថង់ និងកាប់ព្រៃចន្លោះរងកៅស៊ូដាំឆ្នាំ២០១០-២០១៣។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

### ៣.១ ការងារមន្ទីរពិសោធន៍ស្រាវជ្រាវផលិតកម្មសត្វ

- ជ្រូកសរុបចំនួន២២១ក្បាល នៅក្នុងស្ថានីយពិសោធន៍ពូជជ្រូក ក្នុងនោះជ្រូកបាចំនួន១០ក្បាល ជ្រូកមេចំនួន១០១ក្បាល និងកូនជ្រូកចំនួន១១០ក្បាល

- គោសរុបចំនួន១៥៣ក្បាល នៅក្នុងស្ថានីយចិញ្ចឹមគោ ក្នុងនោះគោបាចំនួន៤ក្បាល គោមេប្រាម៉ាន់កាត់ចំនួន៣៥ក្បាល គោជំទង់ចំនួន៣៦ក្បាល គោបៅដោះចំនួន៣៦ក្បាល និងគោកំផែងសែនចំនួន៤០ក្បាល។

### ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

- ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី ជំងឺសារទឹកចំនួន១២៧.៨០២ក្បាល និងជំងឺអុតក្តាមចំនួន៨៧៩ក្បាល

- ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន៧.៨៥០ក្បាល ជំងឺប៉េស្តចំនួន១៣.៦៦៤ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន៨.៨៩៩ក្បាល ជំងឺអុតក្តាមចំនួន៣៩៨ក្បាល ជំងឺអូហ្យេស្គីចំនួន១.៦៣៤ក្បាល ជំងឺរាគកូនជ្រូកចំនួន២.៦០១ក្បាល ជំងឺកញ្រ្ជឹលចំនួន២៤១ក្បាល ជំងឺជាតិដែកចំនួន១.៧១៣ក្បាល និងជំងឺផ្លូវដង្ហើមចំនួន៤៣៦ក្បាល

- ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន២១.៣៦៨ក្បាល ជំងឺញីវកាសចំនួន៣៩.៦០២ក្បាល ជំងឺអាសន្នរោគចំនួន១៤១.៥៧៧ក្បាល និងជំងឺប៉េស្តទាចំនួន១១៧.៦៤៧ក្បាល។

### ៣.៣ ការងារមន្ទីរពិសោធន៍ជាតិស្រាវជ្រាវបសុព្យាបាល

- ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក
- រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ
- អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅតាមខេត្ត-រាជធានី
- បានពិនិត្យវត្ថុវិភាគសរុបចំនួន១.២១៤សំណាក និងផ្ទៃកសរីរោគសាស្ត្រសរុបចំនួន៥ក្បាល
- ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន និងផលិតឡជីវឧស្ម័នសរុបចំនួន១២០ឡ។

### ៣.៤ ការអនុវត្តវិធានបសុពេទ្យ

- តាមដាន ឃ្លាំមើលជាប្រចាំនូវជំងឺផ្តាសាយបក្សីប្រភេទH5N1 និងH7N9 នៅលើទីផ្សាររាជធានី ខេត្តទូទាំងប្រទេស និងទទួលទូរស័ព្ទហៅចូលសរុបចំនួន២ករណី មកពីខេត្តកណ្តាល និងខេត្តកំពង់ធំ សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព រាយការណ៍ពីបក្សីឈឺ ងាប់ និងវិធានការការពារជំងឺផ្តាសាយបក្សី និងចូលរួមអនុវត្តលំហាត់សាកល្បងអមពីជំងឺផ្តាសាយបក្សីនៅខេត្តតាកែវ ដោយមានការចូលរួមពីក្រសួងសុខាភិបាល នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ អង្គការសុខភាពពិភពលោក អង្គការUSAID និងផ្នែកផលិតកម្មនិងបសុព្យាបាលស្រុក

- បើកយុទ្ធនាការផ្សព្វផ្សាយជំងឺផ្តាសាយបក្សីនៅខេត្តព្រៃវែង កំពត ព្រះសីហនុ និងខេត្តបាត់ដំបង សរុបចំនួន៧ករណី ដែលមានអ្នកចូលរួមសរុបចំនួន១៧៧នាក់ រៀបចំផលិតSpot វិធីការពារនិងទប់ស្កាត់ការចម្លងរាលដាលជំងឺផ្តាសាយបក្សី និងរៀបចំផែនការសម្រាប់សកម្មភាពផ្សព្វផ្សាយជាមួយកម្មវិធី EU-PGA-L

- ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមជ្រូកចំនួន៣៥លើក មាន់ចំនួន១០២លើក ទាចំនួន៤៤លើក កន្លែងពិឃាតមាន់ចំនួន៧៦លើក កន្លែងលក់មាន់ចំនួន១៧លើក ទ្រុងចិញ្ចឹមចំនួន៩៧លើក បរិវេណភូមិចំនួន១៨លើក និងសត្តឃាតដ្ឋានចំនួន៦លើក។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជន៖ ឈើហ៊ុបមូលសរុបចំនួន៩៨៧ម៣ ឈើអារចំនួន២៩៤ម៣ កូនឈើចំនួន៥.៦៦៧ដើម អុសចំនួន៥.២០៦ស្ទែរ ជ័រទឹកចំនួន៨០តោន ឫស្សីចំនួន១.៤៥៣តោន ជន្លង់ម្រេចចំនួន៦២៣ដើម និងធ្យូងចំនួន១២តោន

- ពិនិត្យសំណើសុំបង្កើតសហគមន៍ព្រៃឈើចំនួន០៤ របស់ខណ្ឌរដ្ឋបាលព្រៃឈើបាត់ដំបង ក្នុងនោះសហគមន៍ព្រៃឈើចំនួន០២មានទីតាំងជាន់ជាមួយព្រៃឫស្សីសម្បទានក្រុមហ៊ុនភាពីម៉ិច និង០២សហគមន៍ទៀតដែលមានផ្ទៃដីចំនួន៥៧៩,១៤ហិកតា កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍។

### ៤.២ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

- ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង និងកំពង់ធំ-សៀមរាប) ដែលមានសត្វស្លាបប្រមាណ១៩៤ប្រភេទ (ប្រហែល៣៥.១៧៧ក្បាល)

- រៀបចំអាហារដ្ឋានត្មាតចំនួន០២លើកនៅខេត្តស្ទឹងត្រែងនិងខេត្តក្រចេះ និងព្រៃការពារព្រះវិហារ ដោយរាប់ឃើញសត្វត្មាតសរុបចំនួនប្រមាណ៤៣ក្បាល

- ការពារសម្បុកសត្វត្រដក់តូចចំនួន៩១សម្បុក សត្វក្រយ៉ងចង្កំ ក ស ចំនួន៣សម្បុក និងត្មាតផេះចំនួន២ នៅខេត្តព្រះវិហារ ស្ទឹងត្រែង និងក្រចេះ។

### ៤.៣ ការងារអប់រំផ្សព្វផ្សាយនិងបណ្តុះបណ្តាល

- ធ្វើការអប់រំផ្សព្វផ្សាយបានចំនួន៥៥លើក ច្បាប់ស្តីពីព្រៃឈើនិងវ៉េដបូក ការទប់ស្កាត់បទល្មើសព្រៃឈើ-សត្វព្រៃ និងផ្សព្វផ្សាយការងារសហគមន៍ព្រៃឈើ និងការអភិរក្សសត្វស្លាប ដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន៨៤១នាក់ (ស្ត្រីចំនួន២៩៨នាក់)។

### ៤.៤ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្នុងខែវិច្ឆិកា ឆ្នាំ២០១៤នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សា៖ សត្វចំណូលថ្មីចំនួន១៥២ក្បាល សត្វកើតថ្មីចំនួន២០ក្បាល សត្វដោះលែងចំនួន៣៦ក្បាល សត្វស្លាប់ចំនួន៦ក្បាល ព្យាបាលសត្វចំនួន៥៧ក្បាល យកសំណាកទៅពិសោធន៍ចំនួន១១ក្បាល ធ្វើឲ្យសន្លប់ចំនួន១១ក្បាល ទម្លាក់សត្វល្អិតចំនួន៩៣ក្បាល វះកាត់សាកសពសត្វចំនួន៦ក្បាល ជួសជុលផ្លូវចំនួន២.៧០០ម$^{២}$ ស្តារអនាម័យព្រៃចំនួន២៣.៨០០ម$^{២}$ និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន៥៩នាក់

- ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្តាមមេ-បាពូជ និងកូនស្វាក្តាមចំនួន៥៥.៦២៥ក្បាល និងបាននាំចេញចំនួន៣០ក្បាល។

### ៤.៥ គម្រោងអភិរក្សសត្វក្រពើភ្នំកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ

- បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែងឆាយរាប តំបន់ស្តារក្រពើក្នុងឃុំតាតៃលើ ខេត្តកោះកុង និងអូរសោម ខេត្តពោធិ៍សាត់

- តាមដានសត្វក្រពើដែលបានដោះលែង១៥ក្បាល តាមរយៈឧបករណ៍វិទ្យុសំឡេង(Radio Tracking)

- ប្រមូលគ្រាប់ពូជឈើកកោះនៅសហគមន៍ព្រៃឈើនាងកង្រី ខេត្តកំពង់ឆ្នាំង បានចំនួន៥០០គ.ក្រ និងយកមកបណ្តុះជាកូនឈើបានចំនួន២០.០០០ដើមសម្រាប់កម្មវិធីបុណ្យរុក្ខទិវាឆ្នាំ២០១៥

- បន្តថែទាំនិងដាំឈើប្រភេទដូងថែមចំនួន០៥ហិកតាជាចម្ការពូជឈើនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ

- បន្តស្រាវជ្រាវពូជឈើមានដោយកម្រនៅក្នុងតំបន់សហគមន៍ព្រៃឈើនានាសម្រាប់ទិសដៅប្រើប្រាស់គ្រាប់ពូជ។

### ៤.៦ ការងារដាំដើមឈើ

- ការដាំឈើក្នុងពិធីបុណ្យរុក្ខទិវា ការដាំឈើជាចម្ការនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើរបស់រដ្ឋ ក្រុមហ៊ុនឯកជន ក្រុមហ៊ុនដៃគូជាមួយរដ្ឋបាលព្រៃឈើ ផ្នែកឯកជនខ្នាតតូច/ធំ និងអង្គការក្រៅរដ្ឋាភិបាល និងការថែទាំចម្ការឈើចាស់ បានឈូសឆាយដីបានចំនួន២.៩៩២,០៥ហិកតា និងដាំឈើជាចម្ការបានចំនួន២.៨៤២,០៥ហិកតា។

### ៤.៧ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញឈើកែច្នៃជូនក្រុមហ៊ុនចំនួន១ ដែលមានបរិមាណកម្ទេចឈើចំនួន៨៩៩តោន។

### ៤.៨ ការងារចំណូលព្រៃឈើ

- ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន១.០៦៦.៨២៧.១៩៩រៀល និងផ្តល់សេវាសាធារណៈចំនួន១៦.២៦៩,១៤ដុល្លារ និង៥.៤២៦.៤៣២.៣៤៧រៀល។

### ៤.៩ ការងារនីតិកម្មនិងវិវាទ

- បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានទូទាំងប្រទេសចំនួន២៣៩ករណី ដោយបញ្ជូនទៅតុលាការចំនួន១៦៥ករណី និងពិន័យអន្តរការណ៍ចំនួន៧៤ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៣០ម៣ ឈើអារចំនួន១.០២៤ម៣ ឈើក្រាក់គ្រញូងចំនួន៦ម៣និង១.១១៥គ.ក្រ សត្វព្រៃចម្រុះប្រភេទចំនួន៤១៩គ.ក្រនិង៣១៣ក្បាល និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត ដីព្រៃឈើដែលកាប់រានចំនួន១០២ហិកតាត្រូវបានបញ្ជូនសំណុំរឿងទៅតុលាការនិងបានដកហូតរណារយន្តចំនួន០៣គ្រឿង

- បាននឹងដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃដែលបានទទួលទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ(Case Tracking System-CTS) ដើម្បីរៀបចំឲ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប។

## ៥ ផ្នែកផលផល

### ៥.១ អាជីវកម្មនេសាទ

៥.១.១ នេសាទទឹកសាប

- ជាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៣-២០១៤ ក្នុងខែចំនួន១.០០០តោន សរុបបានចំនួន៣.០០០តោន ស្មើ២០% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៥០០តោន

- នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៤ ក្នុងខែចំនួន២០.០០០តោន សរុបបានចំនួន២៦៥.០០០តោន ស្មើ៦៧,៩៥% នៃផែនការ៣៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣៥.០០០តោន

- នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៤ ក្នុងខែចំនួន១៥.០០០តោន សរុបបានចំនួន១១៥.០០០តោន ស្មើ៦៣,៨៩% នៃផែនការ១៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០តោន។

៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៤

- ក្នុងខែចំនួន៩.០០០តោន សរុបចំនួន៩៨.០០០តោន ស្មើ៨៩,០៩% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៨.០០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា ក្នុងខែចំនួន៨.០០០តោន សរុបបានចំនួន៩០.០០០តោន ស្មើ៩០% នៃផែនការ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១៥.០០០តោន

- ការចិញ្ចឹមក្រពើ ក្នុងខែចំនួន១៥.០០០ក្បាល សរុបបានចំនួន២៤៥.០០០ក្បាល ស្មើ៨១,៦៧% នៃផែនការ៣០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០.០០០ក្បាល

- ការភ្ញាស់កូនត្រីពូជ ក្នុងខែចំនួន១០.០០០.០០០កូន សរុបបានចំនួនប្រមាណ១៧៥.០០០.០០០កូន ស្មើ៩៧,២២% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួនប្រមាណ៤៥.០០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៣-២០១៤ ក្នុងខែចំនួន៧.០០០តោន សរុបបានចំនួន៦៥.០០០តោន ស្មើ៤៣,៣៣% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០តោន

- ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៤ ក្នុងខែចំនួន៥០០តោន សរុបបានចំនួន៧.៥០០តោន ស្មើ៩៣,៧៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០០តោន

- ការផលិតទឹកត្រី ក្នុងខែចំនួន២.០០០.០០០លីត្រ សរុបបានចំនួន៦០.០០០.០០០លីត្រ ស្មើ១០០% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ ក្នុងខែចំនួន១.០០០តោន សរុបបានចំនួន១១.០០០តោន ស្មើ៥៥% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០០តោន

- ផលនេសាទកែច្នៃ ក្នុងខែចំនួន៥០០តោន សរុបបានចំនួន៦.០០០តោន ស្មើ៦០% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៨០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- កំណត់ហេតុបទល្មើស សរុបចំនួន២.៦៣៤ករណី ដែលកើតមាននៅតំបន់ទឹកសាប២.៤៥៩ករណី និងតំបន់សមុទ្រ១៧៥ករណី ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៥៧៥ករណី គឺតំបន់ទឹកសាបថយចុះ៦៦៩ករណីនិងតំបន់សមុទ្រថយចុះ៩៤ករណី។ សមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

## ៥.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផល ក្នុងខែចំនួន៨៨.៤៥១.៧៥០រៀល សរុបបានចំនួន២.៩៨០.៩២៦.៥៨៧រៀល ស្មើ៩៧,៩៨% នៃផែនការ៣.០៤២.៥០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២៣៤.៣៤៧.៤៦៦រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះផ្ទៀងផ្ទាត់ព័ត៌មាននិងធ្វើការអង្កេតអំពីខ្សែសង្វាក់ផលិតកម្មដំណាំស្វាយជាមួយកសិករនៅខេត្តបាត់ដំបង
- រៀបចំទិវាស្រែបង្ហាញដែលមានកសិករចូលរួមចំនួន១៤១នាក់ នៅខេត្តស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី និងប្រមូលទិញគ្រាប់ស្រូវផ្ការមៀតរបស់កសិករគោលដៅនៅខេត្តតាកែវ
- ត្រួតពិនិត្យពិសោធន៍ស្រែបង្ហាញ វាយតម្លៃ និងកំណត់ទីតាំងធ្វើពិសោធន៍ និងដំឡើងឧបករណ៍អាកាសធាតុ នៅខេត្តបាត់ដំបង តាកែវ និងខេត្តកែប
- ធ្វើការពិភាក្សាក្រុមកសិករដើម្បីប្រមូលព័ត៌មានអំពីការដាំដុះស្រូវនិងដំណាំរួមផ្សំចំនួន៦ក្រុម ដែលមានកសិករសរុបចំនួន៦៣នាក់ នៅខេត្តតាកែវ កំពង់ស្ពឺ និងខេត្តកំពត
- ត្រួតពិនិត្យនិងតាមដានការងារពិសោធន៍នៅខេត្តកំពង់ឆ្នាំង បាត់ដំបង សៀមរាប ស្ថានីយកោះកេរ្តិ៍ខេត្តព្រះវិហារ និងប្រមូលទិន្នន័យស្តីពីការទទួលយកពូជស្រូវទាំង១០របស់កសិករនៅខេត្តតាកែវ
- ចុះប្រមូលសំណាកពូជដំណាំបន្លែនិងពពួកសណ្តែកព្រៃនៅខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងខេត្តបន្ទាយមានជ័យ។

## ៧ ផ្នែករដ្ឋបាល និងប្រតិបត្តិការអន្តរជាតិ

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានាក្នុងខែចំនួន៥០៩ច្បាប់ សរុបចំនួន៤.៩៨០ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទក្នុងខែចំនួន៤៣៦ច្បាប់ សរុបចំនួន៤.១៥០ច្បាប់ និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន១២៤ច្បាប់ សរុបចំនួន១.៣៥៦ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល
- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៦៨៤ច្បាប់ សរុបចំនួន៧.៥១១ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន៣២ច្បាប់ សរុបចំនួន៦៥២ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន២៥ច្បាប់ សរុបចំនួន៦០៥ច្បាប់
- រៀបចំលិខិតទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីសុំពន្យារនិងផ្តល់លិខិតឆ្លងដែនជូនមន្ត្រីរាជការចំនួន៥ច្បាប់ និងសុំស្លាកលេខសម្រាប់រថយន្តជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន០២គ្រឿង
- សម្របសម្រួលរៀបចំបែបបទ និងគោលការណ៍ជូនថ្នាក់ដឹកនាំក្រសួង ទីប្រឹក្សាបច្ចេកទេស និងមន្ត្រីរាជការក្រោមឱវាទដូចជាលិខិតឆ្លងដែន ពន្យារទិដ្ឋាការស្នាក់នៅ ព្រមទាំងទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាបានចំនួន៤៩រូប នៅក្នុងប្រទេសចំនួន១៣
- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៦២៦នាក់ នារីចំនួន១.២៦៩នាក់ ស្មើនឹង១៩,១៥% រួមមាន៖
  - + អង្គភាពថ្នាក់កណ្តាលចំនួន៤.០៤៤នាក់ ក្នុងនោះនារីចំនួន៧៤២នាក់ ស្មើនឹង១៨,៣៤%
  - + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៥៨២នាក់ ក្នុងនោះនារីចំនួន៥២៧នាក់ ស្មើនឹង២០,៤១%
- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន០៧នាក់ ក្នុងនោះបោះបង់ការងារចំនួន០១នាក់ សុំលាឈប់ពីការងារចំនួន០៥នាក់ និងមរណភាពចំនួន០១នាក់
- ប្រកាសផ្ទេរមន្ត្រីរាជការផ្ទេរចូលក្រសួងចំនួន០១នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន០៦នាក់
- ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន៦០នាក់ និងចូលធ្វើការងារវិញចំនួន០១នាក់

- ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទបានទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន២៤នាក់ និងក្នុងប្រទេសចំនួន០៩នាក់

- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ៩ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ៩.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបចំនួន១.០០៧នាក់(ស្រី៣៣៦នាក់) ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។ បន្តរៀបចំកម្មវិធីសិក្សាថ្មី២០១៤-២០១៥ ព្រមទាំងសិក្សាអំពីលទ្ធភាពកាត់បន្ថយចំនួនម៉ោងនិងក្រេឌីតក្នុងក្របខ័ណ្ឌកំណែទម្រង់កម្មវិធីសិក្សាឲ្យបានល្អប្រសើរ។

### ៩.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបមានចំនួន១.៣៩៥នាក់(ស្រី៥២២នាក់) រួមមានៈ

- និស្សិតអាហារូបករណ៍សរុប១.១៦៩នាក់(ស្រី៤៥៤នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩៤៣នាក់(ស្រី៣៣២នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម២២៦នាក់(ស្រី១២៥នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃ២២៦នាក់ (ស្រី៦៨នាក់) ថ្នាក់បរិញ្ញាចំនួន២១៣នាក់(ស្រី៦៥នាក់) និងថ្នាក់បរិញ្ញារងចំនួន១៣នាក់(ស្រី៣នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។

### ៩.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៤.៧១៦នាក់ (ស្រី១.២៧៦នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល បច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ។

ជារួមគ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើតែងតែបញ្ជូននិស្សិតឲ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញនៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឲ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិពាណិជ្ជកម្មរួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឲ្យកាន់តែទូលំទូលាយ។ ទន្ទឹមនឹងនេះ សាលាជាតិកសិកម្មព្រែកលៀបនិងសាលាជាតិកសិកម្មកំពង់ចាមក៏បានរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការប្រែក្លាយសាលាជាតិកសិកម្មទាំងពីរ ទៅជាវិទ្យាស្ថានជាតិនិងបច្ចេកវិទ្យាជាគ្រឹះស្ថានសាធារណៈរដ្ឋបាល បញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីអនុម័ត។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៤ ត្រូវបានបញ្ចប់ជាស្ថាពរហើយ បើប្រៀបធៀបរយៈពេលដូចគ្នាគឺលើសឆ្នាំមុន១.៦៦៤ហិកតា។ ទន្ទឹមនឹងនោះ នៅតាមបណ្តាខេត្តមួយចំនួនដែលទទួលរងនូវផលប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិនោះ ប្រជាកសិករកំពុងជំរុញការងារប្រមូលផលដំណាំផ្សេងៗនិងស្តារផ្ទៃដីខូចខាត ហើយបាននឹងកំពុងជំរុញការដាំដុះដំណាំស្រូវរដូវប្រាំងយ៉ាងមមាញឹក។ ជាមួយនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការខិតខំថែទាំដំណាំស្រូវ យកចិត្តទុកដាក់លើការគ្រប់គ្រង និងការប្រើ

ប្រាស់ទឹកឲ្យមានប្រសិទ្ធភាព ក៏ដូចជាការថែទាំដំណាំផ្សេងៗ និងរក្សាទឹកទុកឲ្យបានគត់មត់នៅចុងរដូវវស្សា ព្រមទាំងជំរុញការធ្វើកសិកម្មចម្រុះឲ្យអស់ពីលទ្ធភាពដែលមានប្រភពទឹកនៅជិត។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏បានចេញនូវសេចក្តីណែនាំស្តីពីវិធានការទប់ស្កាត់ការបាត់បង់បរិមាណ និងគុណភាពស្រូវរដូវវស្សាឆ្នាំ២០១៤ នៅក្នុងនិងក្រោយពេលប្រមូលផល។

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៤នេះពុំមានផ្ទុះឡើងនូវជំងឺលើសត្វគោ-ក្របីទេ។ ទោះជាយ៉ាងណាមន្ត្រីជំនាញបានចុះពិនិត្យព្យាបាល និងតាមដានលើស្ថានភាពជំងឺសត្វយ៉ាងយកចិត្តទុកដាក់ ហើយក្រសួងក៏បានចាត់ក្រុមការងារចុះណែនាំជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី-ខេត្តឲ្យចុះដល់មូលដ្ឋានជាប្រចាំដើម្បីអន្តរាគមន៍តាមការជាក់ស្តែងដូចជាការចាក់វ៉ាក់សាំង ការធ្វើអនាម័យ និងជីវសុវត្ថិភាពជាដើម។

ដោយឡែក ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល កំពុងស្ថិតនៅតែជាប្រធានបទអាទិភាព ហើយដែលអង្គភាពជំនាញជាសេនាធិការនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែងដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាព។ លើសពីនេះទៅទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគាំទ្រផ្សេងៗក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល។

## IV- **ទិសដៅអនុវត្តបន្ត**

**១.ផ្នែកដាំដុះ** :

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗ

- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអតុល្យភាពស្បៀង (អង្ករ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ ដើម្បីបានផ្តល់កម្រៃបន្ថែមជួយដល់សេដ្ឋកិច្ចគ្រួសារ

- បន្តអប់រំផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការបង្កបង្កើនផល

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ដើម្បីទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការរៀបចំគំរូនៃការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- ត្រៀមប្រជុំបូកសរុបការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៤ នៅចុងឆ្នាំនេះ

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសទៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- ធ្វើការដាំដុះសាកល្បងកូនកៅស៊ូប្រភេទ "Invitro" និងបន្តផ្សព្វផ្សាយអំពីបច្ចេកទេសដ៏មានសារសំខាន់នេះ។

**២.ផ្នែកផលិតកម្មនិងបសុព្យាបាល** :

- ចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺសត្វ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការ

អន្តរាគមន៍តាមជាក់ស្តែង។ ទន្ទឹមនឹងនោះ ត្រូវធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឲ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

- ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី H5N1 និងជំងឺផ្តាសាយ H7N9

- ពង្រឹងត្រួតពិនិត្យចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកក្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត។

**៣.ផ្នែកព្រៃឈើ** :

- ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីវិស័យព្រៃឈើតាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឲ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២។

**៤.ផ្នែកជលផល** :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល

- រៀបចំបោះបង្គោលបេតុងចំនួន១៥០បង្គោលនិងសាងសង់ស្នាក់ការល្បាតចំនួន១៦កន្លែងនៅកន្លែងអភិរក្សជលផល

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ

- រៀបចំនិងអនុវត្តវិធានការការពារដែននេសាទនិងធនធានជលផល

- បន្តស្រាវជ្រាវដកហូតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៤ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទ

គ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទនិងការបង្កើនផលចំណូលថវិកាជាតិ

- បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទដូចខាងលើ។

**៥.ផ្នែកពាក់ព័ន្ធផ្សេងៗ :**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី

- ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

- បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់និងការប្រមូលចំណូលបង់ចូលថវិកាជាតិឲ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមវិស័យទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា និងយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យនិងចាត់វិធានការសមស្របដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីរាជការឲ្យបានហ្មត់ចត់

- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

- បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះ ច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**